## សេចក្តីថ្លែងការណ៍រួម – ករណី Cambodia MEF 08

នេះគឺជាសេចក្តីថ្លែងការណ៍រួម រវាងធនាគារ ខេប៊ី ប្រាសាក់ និងអ្នកដាក់ពាក្យបណ្តឹង ពាក់ព័ន្ធនឹងការវិនិយោគដោយប្រយោលរបស់ IFC ជាមួយធនាគារ ខេប៊ី ប្រាសាក់ តាមរយៈទំនាក់ទំនងហិរញ្ញវត្ថុជាមួយ MEF (គម្រោងរបស់ IFC លេខ #27827)។ ពាក្យបណ្តឹងនេះត្រូវបានសម្គាល់ថាជា «ករណី Cambodia MEF 08»។

ក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃរបស់ការិយាល័យ CAO អ្នកដាក់ពាក្យបណ្តឹង និងអតិថិជនបន្តរបស់ IFC គឺធនាគារ ខេប៊ី ប្រាសាក់ បានបង្ហាញចំណាប់អារម្មណ៍ចង់ចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ក្រោមការសម្របសម្រួលរបស់ការិយាល័យ CAO ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងពាក់ព័ន្ធនឹងធនាគារ ខេប៊ី ប្រាសាក់ ដោយប្រើប្រាស់វិធីសាស្ត្រសហការ។ ភាគីទាំងពីរបានឯកភាពគ្នាលើគោលការណ៍ជាមូលដ្ឋានសម្រាប់ដំណើរការសម្រុះសម្រួលនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥។ ជាលទ្ធផលនៃការចូលរួមដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ភាគីទាំងពីរបានឈានដល់ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ ហើយបានឯកភាពថាការិយាល័យ CAO នឹងពិនិត្យតាមដានការអនុវត្តកិច្ចព្រមព្រៀងដោះស្រាយវិវាទរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៨ ដោយរយៈពេលនៃការពិនិត្យតាមដាននេះអាចមានបន្តទៀត។